វិទ្យាស្ថានភាសាជាតិ រាជបណ្ឌិតសភាកម្ពុជា

# ជីវប្រវត្តិ

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត

# ឡុង សៀម



ព.ស. ២៥៥១ គ.ស. ២០០៧

# អារម្ភកថា

វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ចងក្រងជីវប្រវត្តិរបស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ឡុង សៀម** ដើម្បីរំឭកនឹកគុណចំពោះឯកឧត្តមដែលបានបូជាកម្លាំងកាយ កម្លាំងប្រាជ្ញា ស្មារតី និង ថវិកា បម្រើជាតិមាតុភូមិជាពិសេសនៅក្នុងវិស័យវប្បធម៌ និង វិស័យអក្សរសាស្ត្រខ្មែរ គឺឯកឧត្តមបានបន្សល់ទុកនូវស្នាដៃជាច្រើនសម្រាប់ឱ្យកូនខ្មែរសិក្សា និង ស្រាវជ្រាវ ។

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ឡុង សៀម** ជាគ្រូភាសាខ្មែរមួយរូបនិងជាកុលបុត្រខ្មែរម្នាក់យ៉ាងឆ្នើម ដែលបានរួមចំណែកយ៉ាងច្រើនក្នុងការថែរក្សាប្រពៃណីនិងវប្បធម៌ជាតិ ព្រមទាំងរក្សានូវអត្តសញ្ញាណជាតិមានដូចជា ភាសាខ្មែរ និង សិលាចារឹកខ្មែរបុរាណ ជាដើម ។

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត បានព្យាយាមផ្ទេរនូវចំណេះដឹងដោយសុទ្ធចិត្តក្នុងការបណ្តុះបណ្តាល យុវកុលបុត្រ កុលធីតាខ្មែរឱ្យមានសមត្ថភាព ដើម្បីបន្តការអភិវឌ្ឍវប្បធម៌ និង ភាសាខ្មែរឱ្យរុងរឿងជានិរន្តរ៍ ។

គុណូបការៈនេះ យើងខ្ញុំទាំងអស់គ្នា ក៏ដូចជាមាតុភូមិកម្ពុជាទាំងមូល ចងចាំ និង ដឹងគុណជានិច្ច ចំពោះឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ។

រាជធានីភ្នំពេញ, ថ្ងៃច័ន្ទ ទី១៥ ខែតុលា ឆ្នាំ២០០៧

**វិទ្យាស្ថានភាសាជាតិ**

# ជីវប្រវត្តិ

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ឡុង សៀម**

សមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា

អនុប្រធានរាជបណ្ឌិតសភាកម្ពុជា ទទួលបន្ទុក

កិច្ចការវិទ្យាស្ថានភាសាជាតិ

## ១- ស្រុកកំណើត និង គ្រួសារ

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម កើតនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៣៥ នៅភូមិថ្លា ឃុំច្រនៀង ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ឪពុក ឈ្មោះ ឡុង ច្រឹក ម្ដាយឈ្មោះ រ័ត្ន ស៊ិន។ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ជាកូនច្បងក្នុងចំណោមបងប្អូន៦នាក់មានស្រី២នាក់ ដែលមានឈ្មោះជាបន្ត បន្ទាប់ ប្អូនប្រុសទី១និងប្អូនស្រីទី២ ក្ស័យ ស្លាប់តាំងពីកុមារភាព ប្អូនទី៣ ឈ្មោះ ឡុង អ៊ិន ភេទស្រី (ត្រូវជាម្ដាយបង្កើតរបស់ឯកឧត្តម **ពាក ស៊ុនអ៊ី** ) ស្លាប់នៅឆ្នាំ១៩៧១ ប្អូនទី៤ ឈ្មោះ ឡុង ស៊ី ភេទប្រុស និង ប្អូនទី៥ ឈ្មោះ ឡុង ប៊ុនថា ភេទប្រុស អ្នកទាំងពីរនាក់បានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

## ២- ការសិក្សា

ក្នុងវ័យកុមារ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម រៀននៅ សាលាវត្តថ្លា នៅភូមិថ្លា ឃុំច្រនៀង ស្រុកបារាយណ៍ ខេត្តកំពង់ធំ រួចបន្ត

ការសិក្សានៅសាលាបឋមសិក្សានៅស្រុកបារាយណ៍ និង នៅកំពង់ធំក្រុង ហើយឯកឧត្តម ទទួលបានវិញ្ញាបនប័ត្របឋមសិក្សានៅទីនោះ។

ដោយសារជោគជ័យនៃការសិក្សា ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតទទួលបានសញ្ញាប័ត្រជាបន្តបន្ទាប់ ដូចតទៅ :

- **ឆ្នាំ១៩៥៨** : សញ្ញាប័ត្រគរុកោសល្យ
- **ឆ្នាំ១៩៦១** : សញ្ញាប័ត្រទុតិយភូមិនៅវិទ្យាស្ថានគរុកោសល្យ
- **ឆ្នាំ១៩៦១-១៩៦២** : សញ្ញាប័ត្របរិញ្ញាប័ត្រអក្សរសាស្ត្រខ្មែរ
- **ឆ្នាំ១៩៦២-១៩៦៥** : សញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់(អនុបណ្ឌិត) ចំណងជើងសារណា : *សាកល្បងសិក្សាមហាវេស្សន្តរជាតក*
- **ឆ្នាំ១៩៧១ :** សញ្ញាប័ត្រថ្នាក់បណ្ឌិតនៅវិទ្យាស្ថានបូព៌ានៃបណ្ឌិតសភាវិទ្យាសាស្ត្រសហព័ន្ធរុស្ស៊ី ចំណងជើងនិក្ខេបបទ : *ការស្រាវជ្រាវនិរុត្តវិទ្យានៃភាសាខ្មែរទំនើប*
- **ឆ្នាំ១៩៧៦-១៩៨០ :** ថ្នាក់បណ្ឌិតរដ្ឋនៅសាកលវិទ្យាល័យប៉ារីសស័របោន។

## ៣- ការងារ និង បេសកកម្ម

ទន្ទឹមនឹងជោគជ័យដ៏ត្រចះត្រចង់ក្នុងការសិក្សាខាងលើនេះ ឯកឧត្តម សាស្ត្រាចារ្យបណ្ឌិត ឡុង សៀម ទទួលបានជោគជ័យប្រកបដោយមោទនភាពនៅក្នុងវិជ្ជាជីវៈនិងជាសហការីវិទ្យាសាស្ត្រ ជាអ្នកឯកទេសនៃអង្គការអន្តរជាតិ និង ជាទីប្រឹក្សាវិទ្យាសាស្ត្រជាបន្តបន្ទាប់ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ដូចតទៅនេះ :

-**ឆ្នាំ១៩៥៧ :** ជាសាស្ត្រាចារ្យភាសាខ្មែរ នៅអនុវិទ្យាល័យតាកែវ

-**ឆ្នាំ១៩៦២-១៩៦៥ :** ជាសាស្ត្រាចារ្យភាសា និង អក្សរសិល្ប៍ខ្មែរ នៅវិទ្យាល័យព្រះយុគន្ធរ ក្រុងភ្នំពេញ។

-**ឆ្នាំ១៩៦៥-១៩៦៩ :** ជាសាស្ត្រាចារ្យភាសានិងវប្បធម៌ខ្មែរ តាមព្រះរាជក្រឹត្យលេខ១៦១ PCM/om នៃបេសកកម្មនៅវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃក្រសួងការបរទេសរុស្ស៊ី និង នៅសាកលវិទ្យាល័យរដ្ឋនៃទីក្រុងម៉ូស្គូ។

-**ឆ្នាំ១៩៧១-១៩៩២ :** ចាប់ពីឆ្នាំ១៩៧១មក ឯកឧត្តម ត្រូវបានបណ្ឌិតសភាវិទ្យាសាស្ត្រសហព័ន្ធរុស្ស៊ី ជ្រើសរើសឱ្យធ្វើការជាអ្នកស្រាវជ្រាវភាសាវិទ្យានៅវិទ្យាស្ថានបូព៌ាសាស្ត្រ និង បានតែងតាំងឯកឧត្តមជាព្រឹទ្ធសហការីវិទ្យាសាស្ត្រនៃសហព័ន្ធរុស្ស៊ី។ ស្ថិតក្នុងឋានន្តរសក្តិនេះ ឯកឧត្តម បានទទួលបន្ទុកជាអ្នកដឹកនាំក្រុមអ្នកស្រាវជ្រាវភាសាខ្មែរបុរាណតាមសិលាចារឹក ព្រមទាំងភាសាមន-ខ្មែរនានា នៅក្នុងឥណ្ឌូចិន។ ក្នុងឆ្នាំ១៩៧៦ នៅសាកលវិទ្យាល័យប៉ារីសស័របោន បានអនុញ្ញាតឱ្យឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត រៀបចំនិក្ខេបបទថ្នាក់បណ្ឌិតរដ្ឋស្តីអំពី "ការស្រាវជ្រាវវចនស័ព្ទវិទ្យានៃភាសាខ្មែរ តាមរយៈសិលាចារឹកកម្ពុជាពីសតវត្សទី៦ ដល់ សតវត្សទី១៤"។ បន្ទាប់ពីឆ្នាំ១៩៧៩ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត បានធ្វើជាអ្នកដឹកនាំនិក្ខេបបទថ្នាក់បណ្ឌិតនៃកម្មសិក្សាការីរបស់ប្រទេសកម្ពុជា និង កម្មសិក្សាការីបរទេស ជាពិសេស ជនជាតិរុស្ស៊ី បានជាច្រើននាក់។

-**ឆ្នាំ១៩៧៨** : តាមការអញ្ជើញរបស់គ្រឹះស្ថាន EPHE-Sorbonne រយៈពេលមួយខែ (ខែឧសភា) ចូលរួមធ្វើសិក្ខាសាលាស្តីពី ភាសាវិទ្យា និងសិលាចារឹកវិទ្យា នៅមជ្ឈមណ្ឌលប្រវត្តិសាស្ត្រនិងអារ្យធម៌នៃឧបទ្វីបឥណ្ឌូចិន ប្រទេសបារាំង។

-**ឆ្នាំ១៩៨២-១៩៨៥** : ធ្វើទស្សនកិច្ចនិងធ្វើសិក្ខាសាលាស្តីពី ភាសាវិទ្យា និងប្រវត្តិសាស្ត្រ តាមការអញ្ជើញរបស់ក្រសួងអប់រំ យុវជន និងកីឡា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងឋានៈជាបេសកជននៃវិទ្យាស្ថានបូព៌ានៃបណ្ឌិតសភាវិទ្យាសាស្ត្រសហភាពសូវៀត។

**បញ្ជាក់** : *បន្ទាប់ពីប្រទេសកម្ពុជាបានរំដោះពីរបប ប៉ុល ពត លោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម និងភរិយា ឡុង ភ្លារ៉ា បានរួមចំណែកផ្តួចផ្តើមបង្កើនកិច្ចសហការ ជាមួយនឹងសហភាពសូវៀតក្នុងការបញ្ជូននិស្សិតខ្មែរជាច្រើនទៅសិក្សានៅទីនោះ។*





**-ឆ្នាំ១៩៩៣_១៩៩៤ :** ជាអ្នកឯកទេស TOKTEN (Transfer of Knowledge through Expatriate Nationals) នៃអង្គការសហប្រជាជាតិ និងជាទីប្រឹក្សាវិទ្យាសាស្ត្រ នៅវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនៃក្រសួងអប់រំ យុវជន និង កីឡា។ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ជាសមាជិករួមនៃមជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រ ប្រទេសបារាំង (URA 1075, 22Av. du President Wilson, 7506 Paris) និងជាអ្នកឯកទេសនៃអង្គការ (IOM) សាស្ត្រាចារ្យភាសាវិទ្យា និងសិលាចារឹកវិទ្យានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**-ឆ្នាំ១៩៩៤_១៩៩៦ :** ជាអ្នកពិគ្រោះការនៃគណៈកម្មការកែលម្អប្រព័ន្ធអប់រំនិងជាសមាជិកនៃក្រុមដឹកនាំការងារជាតិសម្រាប់ឧត្តមសិក្សា។

**-ឆ្នាំ១៩៩៥_១៩៩៩ :** ជាអ្នកឯកទេសស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ និងជាទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា ទទួលបន្ទុកដំណើរការ

បង្កើតវិទ្យាស្ថានភាសាជាតិ និង ជាសាស្ត្រាចារ្យភាសាវិទ្យា និង សិលាចារឹកវិទ្យា នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

-**ឆ្នាំ២០០០-២០០៧ :** ជាសាស្ត្រាចារ្យបង្រៀននិងដឹកនាំសារណាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ (Master) និង និក្ខេបបទថ្នាក់បណ្ឌិត នៅរាជបណ្ឌិតសភាកម្ពុជា និង ជាសាស្ត្រាចារ្យបង្រៀននិងដឹកនាំសារណាថ្នាក់បរិញ្ញាប័ត្រ និង ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈផងដែរ។

## ៤- តួនាទីនៅក្នុងរាជរដ្ឋាភិបាល

ដោយមានបទពិសោធន៍យ៉ាងច្រើន ក្នុងវិជ្ជាជីវៈនិងឋានៈខាងលើ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ឡុង សៀម** បានទទួលនូវតួនាទីផ្សេងៗក្នុងក្រសួង ស្ថាប័ននានា និង ក្នុងរាជរដ្ឋាភិបាលកម្ពុជាមានឋានៈជាឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ជាបន្តបន្ទាប់ :

-**ឆ្នាំ១៩៩៦ :** ជាទីប្រឹក្សារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ដើម្បីដំណើរការវិទ្យាស្ថានជាតិភាសាខ្មែរ។

-**ឆ្នាំ១៩៩៧-១៩៩៨ :** ជាទីប្រឹក្សានាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ ទទួលបន្ទុកផ្នែកវប្បធម៌ និង អក្សរសាស្ត្រ និង ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

-**ឆ្នាំ២០០០ :** ទីប្រឹក្សាបច្ចេកទេសរបស់ឯកឧត្តម គុល ប៉ាញ់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ទទួលបន្ទុកប្រធានវិទ្យាស្ថានភាសាជាតិ។

-**ឆ្នាំ២០០១ :** ប្រធានវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើអនុរដ្ឋលេខាធិការ និងជាអនុប្រធានក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាកម្ពុជា។ បន្ទាប់មកនៅក្នុងឆ្នាំនោះដែរ ឯកឧត្តមត្រូវបានតែងតាំងជាសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា។

-**ឆ្នាំ២០០៣ :** ជាសមាជិកគណៈកម្មការវប្បធម៌កម្ពុជា_ថៃ និងជាសមាជិកគណៈកម្មការបណ្ឌិតសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់។

-**ឆ្នាំ២០០៦ :** អនុប្រធានរាជបណ្ឌិតសភាកម្ពុជា ឋានៈស្មើរដ្ឋលេខាធិការ។

-**ឆ្នាំ២០០៧ :** អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិភាសាខ្មែរ។

ក្នុងមួយជីវិតរបស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឯកឧត្តមបានបរិច្ចាគទាំងកម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញា ស្មារតី និង ថវិកាផ្ទាល់ខ្លួនជាច្រើនសម្រាប់បម្រើនៅក្នុងវិស័យវប្បធម៌និងអក្សរសាស្ត្រខ្មែរ ជាពិសេសវិទ្យាស្ថានភាសាជាតិ ដែលឯកឧត្តមជាអ្នកផ្តួចផ្តើមបង្កើត និង ដឹកនាំ។

ឯកឧត្តម បានជំរុញនិងសម្របសម្រួលវិស័យអក្សរសាស្ត្រខ្មែរ ឈានទៅរកឯកភាពក្នុងការប្រើប្រាស់អក្ខរាវិរុទ្ធ ព្រមទាំងបង្កើនការសិក្សាស្រាវជ្រាវលើវិស័យនេះផងដែរ។

ទោះបី ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត មានភារៈកិច្ចច្រើនយ៉ាងនេះក្តីក៏ឯកឧត្តម នៅតែទៅជួយបង្ហាត់បង្រៀននិស្សិត ផ្នែកសិលាចារឹកវិទ្យា ភាសាវិទ្យា

នៅរាជបណ្ឌិតសភាកម្ពុជា និង និស្សិតបុរាណវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ពុំដែលខកខានឡើយ។

ស្នាដៃនៅក្នុងការបំពេញតួនាទីខាងលើ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតបានទទួល :

**-ឆ្នាំ២០០៥ :** ជាវីរសិល្បករ ឯកទេសសិលាចារឹក ពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**-ឆ្នាំ២០០៦ :** គ្រឿងឥស្សរិយយសមុនីសារភ័ណ្ឌ ថ្នាក់ធិបឌិន្ទ ពីរាជរដ្ឋាភិបាលកម្ពុជា។

## ៥- ស្នាដៃបោះពុម្ពផ្សាយជាភាសាខ្មែរ

ស្នាដៃបោះពុម្ពផ្សាយជាភាសាខ្មែរមានជាបន្តបន្ទាប់ ដូចតទៅ :

**-ឆ្នាំ១៩៦៥ : សាកល្បងសិក្សារឿងមហាវេស្សន្តរជាតក**, រោងពុម្ពសំបូរ បោះពុម្ពលើកទី២ ឆ្នាំ១៩៦៦, ភ្នំពេញ ១៤០ ទំព័រ។

**-ឆ្នាំ១៩៦៩ : *សៀវភៅសិក្សាភាសាខ្មែរ***, បោះពុម្ពផ្សាយដោយ វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ, ម៉ូស្គូ, ១២០ ទំព័រ។

**-ឆ្នាំ១៩៨៥ : ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា** (ជាអ្នករៀបរៀង-បកប្រែ), អង្គការបោះពុម្ពផ្សាយ "ប្រូហ្គ្រេស្ស" ម៉ូស្គូ, ៥៨៤ ទំព័រ។

**-ឆ្នាំ១៩៨៦ :**

**-*វាក្យស័ព្ទសំស្ក្រឹតដំបូងក្នុងភាសាខ្មែរបុរាណ និង ស្ថាននាមវិទ្យាខ្មែរ*** មានប្រភពចេញមកពីភាសាសំស្ក្រឹត, ចុះផ្សាយដោយទស្សនាវដ្ដី

កម្ពុជសុរិយា ឆ្នាំទី៥០ លេខ១ ព.ស. ២៥៤០។

-**ស្ថាននាមវិទ្យា** : ចុះផ្សាយដោយទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំទី ៥០ លេខ២ និង លេខ៣ ព.ស. ២៥៤០។

-**នរនាម និង ឋានន្តរនាម** តាមសិលាចារឹកកម្ពុជាសម័យមុនអង្គរ (សតវត្សទី៦ ដល់ទី៨) : ចុះផ្សាយដោយទស្សនាវដ្ដីកម្ពុជាសុរិយា ឆ្នាំ ទី៥០ លេខ៤ ព.ស. ២៥៤១។

**-ឆ្នាំ១៩៩៧**

-**ឋានន្តរនាមសម័យមុនអង្គរ** (សតវត្សទី៦ ដល់ទី៨) : ចុះផ្សាយដោយទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំទី៥១ លេខ១ ព.ស. ២៥៤០។

-**ទម្រង់វេយ្យាករណ៍នៃនរនាម** (តាមឯកសារសិលាចារឹកកម្ពុជា),ចុះផ្សាយដោយទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំទី៥១ លេខ២ ព.ស. ២៥៤១។

-**ពាក្យរណ្តំបរិវារស័ព្ទក្នុងភាសាអក្សរសិល្ប៍ខ្មែរ** : ចុះផ្សាយដោយទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំទី៥១ លេខ២ ព.ស. ២៥៤១។

-**ស្ថាននាមវិទ្យាខ្មែរ** តាមឯកសារសិលាចារឹកប្រទេសកម្ពុជា (សតវត្សទី៦ដល់ទី១៤) : បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៥១ ទំព័រ។

-**ឆ្នាំ១៩៩៩ :**

**.សិលាចារឹករកឃើញថ្មី ឆ្នាំ១០១៤**, ចុះផ្សាយដោយទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំទី៥៣ លេខ២ ព.ស. ២៥៤៣។

**.វចនសព្ទវិទ្យាខ្មែរ :** រោងពុម្ពភ្នំពេញ, ១១៣ ទំព័រ។

-**ឆ្នាំ២០០០ :**

**.វចនានុក្រមខ្មែរបុរាណ** (តាមសិលាចារឹកបុរេអង្គរ សតវត្សទី៦ ដល់ទី៨) មានការបកប្រែជាភាសាបារាំង ឧបត្ថម្ភដោយមូលនិធិ តូយ៉ូតា ជប៉ុន, រោងពុម្ពភ្នំពេញ, ៧៣០ ទំព័រ។

**.សិក្សាកថា សិលាចារឹករកឃើញថ្មីរបស់ព្រះបាទសូរ្យវរ្ម័នទី១** (នៅសារមន្ទីរអភិរក្សអង្គរ) ចុះផ្សាយដោយទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា លេខ១ ឆ្នាំ២០០០។

-**ឆ្នាំ២០០២ : នាយករៀបរៀងបទសម្ភាសនាទីអក្សរសាស្ត្រខ្មែររបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត**។

-**ឆ្នាំ២០០៥ : និពន្ធនាយកវចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ**។

-**ឆ្នាំ២០០៧ : និពន្ធវចនានុក្រមខ្មែរបុរាណ** (តាមសិលាចារឹកសម័យអង្គរ សតវត្សទី៩ ដល់ទី១៤) ប្រហែល ២០០០ ទំព័រ (មិនទាន់ចប់)។

-និងស្នាដៃដទៃទៀត។

## ៦- ស្នាដៃបោះពុម្ពផ្សាយជាភាសា រុស្ស៊ី បារាំង

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត មានស្នាដៃមួយចំនួនទៀតដែលបានបោះពុម្ពផ្សាយជាភាសារុស្ស៊ីនិងភាសាបារាំង មានដូចខាងក្រោម :

-**ឆ្នាំ១៩៧៥ : បញ្ញានិរុត្តិវិទ្យានៃភាសាខ្មែរទំនើប :** រោងពុម្ព ណាអ៊ូកា ម៉ូស្គូ, ១៣១ ទំព័រ (ជាភាសារុស្ស៊ី )។

-**ឆ្នាំ១៩៧៦ :**

-**ឡិចសែមដើមនិងដែនសេម៉ង់ទិកនៅក្នុងភាសាខ្មែរ** ឯកសារសមាជទី៣៩ អ្នកប្រាជ្ញខាងបូព៌ាវិទ្យា, ខ្សែទី២, ប៉ារីស (ជាភាសាបារាំង)។

-**នវនាមតាមសិលាចារឹកកម្ពុជា** ឯកសារសមាជទី៣៩ អ្នកប្រាជ្ញខាងបូព៌ាវិទ្យា, ខ្សែទី២, ប៉ារីស (ជាភាសាបារាំង)។

-**ឆ្នាំ១៩៨១ : ទំនាក់ទំនងអន្តរប្រព័ន្ធរវាងភាសាខ្មែរ_មន** ព្រឹត្តិប័ត្រសាលាចុងបូព៌ា, ខ្សែទី៧០ ប៉ារីស (ជាភាសាបារាំង)។

-**ឆ្នាំ១៩៨៤ : វចនានុក្រមខ្មែរ_រុស្ស៊ី** (អ្នកនិពន្ធ យូរី ហ្គ័ហ្គោនី, រៀបរៀងដោយ ឡុង សៀម), រោងពុម្ព ណាអ៊ូកា, ម៉ូស្គូ, ៩៨៣ ទំព័រ។

-**ឆ្នាំ១៩៨៧ : វចនានុក្រមរុស្ស៊ី_ខ្មែរ** (អ្នកនិពន្ធ ឡុង សៀម និង អ្នកស្រី រ៉ូសាឡាំ), រោងពុម្ព រូស្គីយ៉ាស៊ិក, ម៉ូស្គូ, ៧០៩ ទំព័រ។

-**ឆ្នាំ១៩៨៩ : ស្ថានភាពនិងតថភាពខាងសង្គម_សេដ្ឋកិច្ចនិងវប្បធម៌នៃប្រទេសកម្ពុជាបុរាណ** (តាមអត្ថបទសិលាចារឹក) សន្និសីទទី១ រវាងបារាំង_សូវៀត ស្តីពីអាស៊ីអាគ្នេយ៍ ម៉ូស្គូ (ភាសារុស្ស៊ី_បារាំង )។

-**ឆ្នាំ១៩៩០ : លក្ខណៈពិសេសខ្លះៗនៃវេយ្យាករណ៍ខ្មែរបុរាណ**

ចុះផ្សាយដោយទស្សនាវដ្តីសិក្សាមន-ខ្មែរ លេខ២០ ឆ្នាំ១៩៩០ បាងកក (ជាភាសាបារាំង)។

**-ឆ្នាំ១៩៩១ :**

**-ការសិក្សាអំពីវេយ្យាករណ៍ និង និរុត្តវិទ្យាភាសាខ្មែរ** តាមរយៈសិលាចារឹកកម្ពុជា : រោងពុម្ព ណាអ៊ូកា, ម៉ូស្គូ,១១៤ ទំព័រ។

**-វចនានុក្រមភាសាខ្មែរបុរាណ** (តាមសិលាចារឹកកម្ពុជា សតវត្សទី៦ ដល់ទី១៤) ភាសាបារាំង-រុស្ស៊ី ២៥០០ទំព័រ។ វចនានុក្រមនេះ បានរៀបចំតាំងពីឆ្នាំ១៩៧៣ ហើយបានរក្សាទុកនៅបណ្ណាល័យមជ្ឈិមនៃបណ្ឌិតសភាវិទ្យាសាស្ត្ររុស្ស៊ី ចុះលេខ៤៦៨១៨។

**-ឆ្នាំ១៩៩៨ : មុខងារខាងកម្លាយពាក្យសព្ទនៃបុព្វបទ និង អន្តរបទនៅក្នុងការបង្កើតពាក្យក្នុងភាសាខ្មែរបុរាណ** តាមសិលាចារឹកកម្ពុជាពីស.វ.ទី៦-ទី១៤កម្រងនិក្ខេបបទនៃសន្និសីទអន្តរជាតិ ខាងខេមរវិទ្យា ភាគទី១ ភ្នំពេញ (ជាភាសាបារាំង)។

## ៧- ស្ថានភាពគ្រួសារ

**-ឆ្នាំ១៩៥៥ :** រៀបអាពាហ៍ពិពាហ៍ជាមួយ កញ្ញា ឃ្លាំខ រសៅថន ជាគ្រូបង្រៀន មានកូនស្រីម្នាក់ឈ្មោះ ឡុខ សុគន្ធា កើតនៅឆ្នាំ១៩៥៧។

**-ឆ្នាំ១៩៧៧ :** ម្តាយនិងកូន បានស្លាប់ (ម្តាយស្លាប់មុនកូនមួយថ្ងៃ) ក្នុង

របប ប៉ុល ពត នៅភូមិឈើទាលភ្លោះ ឃុំឆក់កន្ទោង ស្រុកឆ្លូង ខេត្តក្រចេះ។



-បន្ទាប់មក : មានភរិយានាម ឡុខ ភ្លារ៉ា ជនជាតិរុស្ស៊ី។

-**ឆ្នាំ២០០៤** : លោកជំទាវ ឡុខ ភ្លារ៉ា បានធ្វើមរណកាល។



**-ឆ្នាំ២០០៥ :** លោកជំទាវ ឡុង ខណ្ណា ជាភរិយាចុងក្រោយ។ លោកជំទាវមានបុត្រីម្នាក់ឈ្មោះ ឡុង លក្ខិណា។



ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម មានសីលធម៌ខ្ពង់ខ្ពស់ជាគំរូគួរឱ្យយើងទាំងអស់គ្នាគោរពនិងយកតម្រាប់តាម។ ឯកឧត្តមគោរព ឱ្យតម្លៃនិងលើកតម្កើងស្ត្រីជាធំក្នុងជីវិតរបស់ឯកឧត្តម។

## ៨- ស្ថានភាពមុនពេលទទួលមរណភាព

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម បានទៅចូលរួមសន្និសីទមួយនៅទីក្រុងប៉ារីស ពេលនោះឯកឧត្តមមានជំងឺជាទម្ងន់ ត្រូវចូលមន្ទីរពេទ្យដើម្បីវះកាត់ជាបន្ទាន់។ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ត្រូវបានលោក

សាស្ត្រាចារ្យបណ្ឌិត **ឃីន សុខ** និងភរិយា ព្រមទាំងបងប្អូនខ្មែរមួយចំនួនទៀតនៅប្រទេសបារាំង ជួយជ្រោមជ្រែងក្នុងពេលដែលឯកឧត្តមសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ។ ក្រោយពីព្យាបាលរួចមក សុខភាពរបស់ឯកឧត្តមល្អជាធម្មតា។

លុះនៅឆ្នាំ២០០៧ ក្នុងខែមីនា ឯកឧត្តមចាប់ផ្តើមមិនស្រួលខ្លួន ហើយសុខភាពចាប់ផ្តើមចុះខ្សោយរហូតដល់ចុងខែមីនា។ បន្ទាប់មក ឯកឧត្តបានធ្វើដំណើរទៅប្រទេសវៀតណាមដើម្បីពិនិត្យសុខភាព។ ពេលត្រឡប់មកពីប្រទេសវៀតណាមវិញ ជំងឺឯកឧត្តមមិនបានធូរស្បើយឡើយ ហើយចេះតែទ្រុឌទ្រោមទៅៗ។ នៅក្នុងខែមេសា ឯកឧត្តមបានធ្វើដំណើរទៅប្រទេសថៃដើម្បីព្យាបាលរោគនៅមន្ទីរពេទ្យបាងកក អស់រយៈពេលជាង១ខែ។ នៅចុងខែឧសភា ឯកឧត្តមបានវិលត្រឡប់មកមាតុភូមិវិញ ជាមួយនិងសភាពជំងឺយ៉ាប់យ៉ឺនដើរលែងរួច។ ក្នុងខែមិថុនាឆ្នាំដដែល បន្ទាប់ពីត្រឡប់មកពីទីក្រុងបាងកកម្តងទៀត ឯកឧត្តមបានចូលសម្រាកព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យកាល់ម៉ែត ប៉ុន្តែសភាពជំងឺដ៏ធ្ងន់ធ្ងររបស់ឯកឧត្តមនៅតែពុំបានធូរស្បើយឡើយ។

នៅព្រឹកថ្ងៃអាទិត្យ ទី១៥ ខែកក្កដា ឆ្នាំ២០០៧ វេលាម៉ោង ៧ព្រឹក ក្រុមគ្រួសារ កូនក្មួយ មិត្តភក្តិនិងសហការីនៃវិទ្យាស្ថានភាសាជាតិ សម្រេចចិត្តសុំការអនុញ្ញាតពីគ្រូពេទ្យ យករូបឯកឧត្តមចេញពីមន្ទីរពេទ្យត្រឡប់មកកាន់គេហដ្ឋានឯកឧត្តមវិញ ដើម្បីរៀបចំពិធីតាមបែបព្រះពុទ្ធសាសនានិងទំនៀមទម្លាប់ប្រពៃណីខ្មែរ។

អនិច្ចាសង្ខារមិនទៀង វេលាម៉ោង៨ និង ៣៥ នាទីព្រឹក នាថ្ងៃដដែល ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម បានលាចាកលោកយើងនេះ ចោលភរិយា កូនក្មួយ សាច់ញាតិ មិត្តភក្តិ អ្នករួមការងារ និង សហការី វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ក៏ដូចជានិស្សិតទាំងឡាយរបស់ឯកឧត្តម ក្រោមទំនួញសោកសៅ ស្តាយស្រណោះ អាឡោះអាល័យជាពន់ពេក។

**<u>បញ្ជាក់</u>** *ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម កើតថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៣៥ នៅពេលឯកឧត្តមទទួលមរណភាពចំថ្ងៃខែកំណើតរបស់ឯកឧត្តមដដែល។*

ទោះបីជំងឺបៀតបៀនយ៉ាងណាក្តី ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតមិនភ្លេចពីភារកិច្ចនិងកាតព្វកិច្ច ដែលរាជរដ្ឋាភិបាលប្រគល់ជូនម្តងណាឡើយ។ ឯកឧត្តមនៅតែបារម្ភនិងសួរជានិច្ចពីការងារទាំងឡាយ ដែលមិនទាន់បានធ្វើ និងកំពុងធ្វើ។ ម្យ៉ាងទៀត ឯកឧត្តមមិនដែលត្អូញត្អែរពីបញ្ហាសុខភាព ដោយមិនចង់រំខានដល់ញាតិមិត្ត ឬ សហការីទាំងឡាយដែលមកសួរសុខទុក្ខ។

## ៩- ស្ថានភាពក្រោយពេលទទួលមរណភាព

ក្រោយពេល ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម ទទួលមរណភាព ដំណឹងបានផ្សព្វផ្សាយទៅគ្រប់ទិសទីនៃមជ្ឈដ្ឋានថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ក្នុងរាជរដ្ឋាភិបាល ព្រមទាំងញាតិមិត្តនិងនិស្សិតរបស់ឯកឧត្តម។

ស្ថាប័នជាតិជាន់ខ្ពស់មួយចំនួន បានដឹកនាំប្រតិភូមកគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម។ សិស្សគណទាំងឡាយរបស់ឯកឧត្តមគ្រប់លំដាប់ថ្នាក់ មានទាំងមន្ត្រីស្ថានទូតបរទេសនានា អ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ អញ្ជើញមកចូលរួមបំពាក់កម្រងផ្កានិងគោរពវិញ្ញាណក្ខន្ធ ជូនសពឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត។

ឯកឧត្តម ខួន ញឹល ជាអនុប្រធានទី១នៃរដ្ឋសភាជាតិ ក្នុងនាមសាច់ញាតិនិងជាអ្នកតំណាងរដ្ឋសភាជាតិ បានដឹកនាំគណៈប្រតិភូចូលរួមសម្តែងមរណទុក្ខគោរពវិញ្ញាណក្ខន្ធសព និង បំពាក់កម្រងផ្កា។



ឯកឧត្តម សេង លំនៅ តំណាងដ៏ខ្ពស់ខ្ពង់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ស៊ន សំណាង ប្រធានរាជបណ្ឌិតសភាកម្ពុជា អញ្ជើញ

មកបំពាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធ និង បំពាក់មេដាយកិត្តិយសរាជរដ្ឋា-ភិបាលថ្នាក់ធិបឌិន្ទ ជាកិច្ចបច្ឆាមរណៈដើម្បីផ្តល់កិត្តិយសជូនសព និង ជាកិច្ចដឹងនូវឧបការគុណរបស់រាជរដ្ឋាភិបាលចំពោះសពឯកឧត្តម។



ឯកឧត្តម សាយ ឈុំ ប្រធានគណៈប្រចាំការគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា បានចូលរួមសម្តែងមរណទុក្ខគោរពវិញ្ញាណក្ខន្ធសព និង បំពាក់កម្រងផ្កា។

ឯកឧត្តម ប៉ែន បញ្ញា សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជាក្នុងនាមគណបក្សប្រជាជនកម្ពុជា បានដឹកនាំគណៈប្រតិភូចូលរួមសម្តែងមរណទុក្ខ គោរពវិញ្ញាណក្ខន្ធសព និងបំពាក់កម្រងផ្កា។



ឥស្សរជនឆ្នើមៗជាច្រើនរូប និង មិត្តភក្តិមានដូចជា ឯកឧត្តមរដ្ឋមន្ត្រី ស៊ុំ ម៉ានិត ទីប្រឹក្សារាជរដ្ឋាភិបាល ឯកឧត្តមស្ថាបត្យករដ៏ឆ្នើម វណ្ណ ម៉ូលីវណ្ណ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ព្រុំ ម៉ល់ ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម ថៅ ប៉េងលាត ឯកឧត្តមបណ្ឌិត វ៉ែន ស៊ីម៉ន ឯកឧត្តម ឈន អៀម សាស្ត្រាចារ្យបណ្ឌិត ឃីន សុខ ឯកឧត្តមបណ្ឌិតរដ្ឋ គិច សំណាង ឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត សំ សោភាន់ លោកជំទាវសាស្ត្រាចារ្យបណ្ឌិត ខ្លូត ធិតា ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ជា ណេង ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត រស់ ចន្ត្រាបុត្រ ជាអនុប្រធានរាជបណ្ឌិតសភាកម្ពុជា ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ស៊ុំ ឈុំប៊ុន អគ្គលេខាធិការនៃរាជបណ្ឌិតសភាកម្ពុជា ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាប៊ូ អូហ្សាណូ អគ្គលេខាធិការរងនៃរាជបណ្ឌិតសភាកម្ពុជា ឯកឧត្តម ហោរ ឡូត ឯកឧត្តម អ៊ុក វណ្ណារិទ្ធិ លោកជំទាវ ឡឺបោណឺ ស៊ីផារ លោកសាស្ត្រាចារ្យ

មៀច ប៉ុណ្ណ លោកសាស្ត្រាចារ្យបណ្ឌិត សុខ ទូច អនុប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា លោកស្រីសាស្ត្រាចារ្យបណ្ឌិត សាក់ ម៉ិនឆានី លោក ហ៊ុល ថុល បានអញ្ជើញចូលរួមផងដែរ។

វិទ្យាស្ថានភាសាជាតិ និង ក្រុមគ្រួសារសព បានផ្តួចផ្តើមទាក់ទងតំណាងស្ថាបត្យករនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ តាមរយៈលោកសាស្ត្រាចារ្យ ឡេា សាន ដោយសហការជាមួយលោក លឹម សូត្រាក និងលោក អុំ ម៉ិនធឿន ឱ្យជួយគូរគំរូបួង់ចេតិយឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតនៅពេលបុណ្យសព៧ថ្ងៃ។

ក្រុមគ្រួសាររបស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត បានសម្រេចបញ្ចុះសពឯកឧត្តមនៅក្នុងទីធ្លានៃភូមិគ្រឹះផ្ទាល់។

*មតិបញ្ញវន្តជាច្រើន បានស្នើសុំឱ្យរាជរដ្ឋាភិបាល ជាពិសេសស្ថាប័នរាជបណ្ឌិតសភាកម្ពុជា គួរតែគិតគូរសាងរូបសំណាករបស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតតម្កល់ទុកនៅរាជបណ្ឌិតសភាកម្ពុជា ឬ នៅសារមន្ទីរជាតិ ដើម្បីកំណត់ថាជាវរជនឆ្នើមផ្នែកអក្សរសាស្ត្ររបស់ប្រទេស។*

បណ្តាញសារព័ត៌មានជាតិនិងអន្តរជាតិមានដូចជា វិទ្យុអាស៊ីសេរី វិទ្យុ (VOA) ទូរទស្សន៍ កាសែត បានផ្សព្វផ្សាយពីដំណឹងមរណភាពរបស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម។

ការបាត់បង់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម ប្រៀបបីដូចជាការបាត់បង់បណ្ណាល័យមួយ ដែលគួរឱ្យសោកស្តាយជាទីបំផុត។

សូមវិញ្ញាណក្ខន្ធឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម ទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

# ១០-ទំព័ររូបថត



លោកបណ្ឌិត ឡុង សៀម រួមជាមួយគណៈប្រតិភូ ពេលគាល់
ព្រះករុណាព្រះបាទនរោត្តម សីហនុ និង ព្រះអគ្គមហេសី



លោកបណ្ឌិត ឡុង សៀម ធ្វើបដិសណ្ឋារកិច្ចសមមិត្ត ហេង សំរិន ប្រធានក្រុមប្រឹក្សាប្រជាជន
បដិវត្តន៍នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា



លោកស្រី ឡុង សៀម ក្លារ៉ា ធ្វើបដិសណ្ឋារកិច្ចគណៈប្រតិភូកម្ពុជា
មាន សមមិត្ត ចាន់ វ៉ែន និង សមមិត្ត សុខ អាន



លោកបណ្ឌិត ឡុង សៀម និង សមមិត្តរដ្ឋមន្ត្រី ប៉ែន ណាវុឌ្ឍ ចុះហត្ថលេខាលើ
កិច្ចសហប្រតិបត្តិការ ផ្នែកអប់រំ រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និង សហភាពសូវៀត



ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម នៅសារមន្ទីរក្រុងបាងកក



រូបពីឆ្វេងទៅស្តាំ : លោកសាស្ត្រាចារ្យ ម៉រ, ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម
និង លោកសាស្ត្រាចារ្យបណ្ឌិត អ៊ីវ ច័ន



រូបពីឆ្វេងទៅស្តាំ : លោកសាស្ត្រាចារ្យបណ្ឌិត ផែល ថោង ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត
ឡុង សៀម និង លោកសាស្ត្រាចារ្យបណ្ឌិត អ៊ីវ ច័ន សិក្ខាសាលានៅទីក្រុងបាងកក



សិក្ខាសាលានៅទីក្រុងបាងកក




ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម និង លោកសាស្ត្រាចារ្យ សន ពៅ "ស្តីអំពីបញ្ហា អក្សរសាស្ត្រខ្មែរ"
ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ នៅក្នុងកម្មវិធីយល់ដឹងសាកលនៃទូរទស្សន៍បាយ័ន



លោកសាស្ត្រាចារ្យ ឡុង សៀម និង ក្រុមគ្រួសារ មុនពេលចេញដំណើរទៅ
បំពេញបេសកកម្ម (បង្រៀនភាសាខ្មែរ) នៅសហភាពសូវៀត




លោកសាស្ត្រាចារ្យ ឡុង សៀម និង ភរិយា ឃ្លាំង សៅថន ព្រមទាំងបុត្រី
ពេលឡើងយន្តហោះ ធ្វើដំណើរទៅកាន់សហភាពសូវៀត



រូបពីឆ្វេងទៅស្តាំ : អ្នកស្រី ឃ្លាំង សៅថន , បុត្រី និង លោកសាស្ត្រាចារ្យ ឡុង សៀម



រូបពីឆ្វេងទៅស្តាំ : លោកស្រី ឡុង ក្លារ៉ា និង លោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម




រូបពីឆ្វេងទៅស្តាំ : ឯ.ឧ. សាស្ត្រាចារ្យបណ្ឌិត ឡុង សៀម លោកជំទាវ ឡុង វណ្ណា និងអ្នកស្រី លាង វ៉ានី នៅមន្ទីរពេទ្យវៀតណាម FV ក្រុងហូជីមិញ



ឯ.ឧ. សាស្ត្រាចារ្យបណ្ឌិត ឡុង សៀម និង ក្មួយៗ



រូបពីឆ្វេងទៅស្តាំ ៖ ព្រឹទ្ធាចារ្យ ឆេង ផុន បណ្ឌិត ឡុង សៀម និង អ្នកស្រី ឡុង ក្លារ៉ា



រមណីដ្ឋានគីរីរម្យ នៅពេលទិវាសិទ្ធិនារី ថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៧

រូបថតខាងក្រោមនេះ ជាទិដ្ឋភាពថ្ងៃបុណ្យសព











ឯ. ឧ. តាក ស៊ុនអ៊ី និង ប្អូនបង្កើត ប្អូនជីដូនមួយ ព្រមទាំងលោកជំទាវ ឡុង វណ្ណា និង បុត្រី



ឯ. ឧ. តាក ស៊ុនអ៊ី និង លោកជំទាវ, កូន, ប្អូន, ក្មួយ ព្រមទាំងក្រុមគ្រួសារ





















## ១១-បញ្ជីរាយនាមសប្បុរសជនចូលរួមក្នុងការបោះពុម្ព

| | | |
|---|---|---|
| ១.ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត | ឆយ យីហ៊ាង | ១០០ ដុល្លារអាមេរិក |
| ២.ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត | ស៊ិន សំណាង | ១០០ ដុល្លារអាមេរិក |
| ៣.ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត | ព្រុំ ម៉ល់ | ៥០ ដុល្លារអាមេរិក |
| ៤.ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត | អ៊ីវ ច័ន | ៥០ ដុល្លារអាមេរិក |
| ៥.ឯកឧត្តម | តាក ស៊ុនអ៊ី | ៥០ ដុល្លារអាមេរិក |
| ៦. ឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត | សំ សោភាន់ | ២០ ដុល្លារអាមេរិក |
| ៧.ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត | ស៊ុំ ឈុំប៊ុន | ១០០.០០០រៀល |
| ៨.លោកជំទាវ | ឡីបោណី ស៊ីផារ | ២០.០០០ រៀល |
| ៩.លោកសាស្ត្រាចារ្យបណ្ឌិត | ស៊ុន សូត្រ | ៥០.០០០ រៀល |
| ១០.លោកសាស្ត្រាចារ្យបណ្ឌិត | ហ៊ឹម សុភី | ២០ ដុល្លារអាមេរិក |
| ១១. លោកសាស្ត្រាចារ្យ | មៀច ប៊ុណ្ណ | ៥ ដុល្លារអាមេរិក |
| ១២.លោកសាស្ត្រាចារ្យ | សន ពៅ | ១៥ ដុល្លារអាមេរិក |
| ១៣.លោកសាស្ត្រាចារ្យ | ជួរ គារី | ១៥ ដុល្លារអាមេរិក |
| ១៤.លោកសាស្ត្រាចារ្យ | លាង សុភាព | ១០ ដុល្លារអាមេរិក |
| ១៥.លោក | លី សុធីរ័ត្ន | ១០ ដុល្លារអាមេរិក |
| ១៦.លោកសាស្ត្រាចារ្យ | មាឃ បូរ៉ា | ៥ ដុល្លារអាមេរិក |
| ១៧.លោកសាស្ត្រាចារ្យ | ណុន សុខា | ៥ ដុល្លារអាមេរិក |
| ១៨.លោកសាស្ត្រាចារ្យ | ប៊ី សុខគង់ | ៥ ដុល្លារអាមេរិក |
| ១៩.លោកសាស្ត្រាចារ្យ | សេ អឿន | ៥ ដុល្លារអាមេរិក |
| ២០.អ្នកស្រី | ហង់ ថាវី | ៥ ដុល្លារអាមេរិក |
| ២១.អ្នកស្រី | តិប ស៊ីណា | ៥ ដុល្លារអាមេរិក |
| ២២.កញ្ញា | ចូន សុគន្ធី | ៥ ដុល្លារអាមេរិក |
| ២៣.លោកសាស្ត្រាចារ្យ | វង្ស មេង | ៥ ដុល្លារអាមេរិក |
| ២៤.លោកសាស្ត្រាចារ្យ | ត្រឹង លីម | ២០.០០០ រៀល |
| ២៥.លោកសាស្ត្រាចារ្យបណ្ឌិត | ឆេង វណ្ណារិទ្ធ | ២០.០០០ រៀល |